lេខ/No: D93/I

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាសម្រេចលើពាក្យសុំកិច្ចស៊ើបសួរ

## Ordonnance sur demandes d'actes d'instruction

## Order concerning Requests for Investigative Actions

យើង **យូ ប៊ុនឡេង** និងMarcel Lemonde (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

បានឃើញវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២
ត្រូវបានដាក់អោយស្ថិតក្រោមការពិនិត្យចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញពាក្យសុំចុះថ្ងៃទី ២ ខែមិថុនា ឆ្នាំ២០០៨ ដោយមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី **ក...** និងលោក **ខ...** ដែលបានស្នើអោយសួរចម្លើយជនត្រូវចោទអំពីសាច់ញាតិរបស់ពួកគេ (មានលោក **គ...** និង មានលោក **ឃ...** លោក **ង...** និងប្រពន្ធរបស់គាត់គឺលោកស្រី **ច...**) ដែលបានស្លាប់នៅ ស-២១។

## សំអាងហេតុនៃសេចក្ដីសម្រេច

យល់ឃើញថាការស្នើសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមានការត្រឹមត្រូវស្របច្បាប់ ហើយត្រូវតែផ្ដល់អោយក្នុងរបៀបណាមួយ។

ប៉ុន្តែ យល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានករណីយកិច្ចរៀបចំអោយមានដំណាក់កាលសវនាការដោយមិនមានការយឺតយ៉ាវ ក្នុងផលប្រយោជន៍ដំណើរការល្អនៃយុត្តិធម៌ និង ជាផលប្រយោជន៍របស់ភាគីផ្ទាល់ផងដែរ។ ដោយយល់ឃើញថា ការបើកការស៊ើបសួរឡើងវិញក្នុងដំណាក់កាលនេះ នឹងមានផលវិបាកចំបង ដោយពិចារណាទៅលើការធាក់ថយក្រោយនៃដំណើរការនីតិវិធី និងការចោទជាបញ្ហាចំពោះប្រតិទិនការងារដែលបានគ្រោងទុក ដែលជាការលំបាកដើម្បីអោយមានការបើកសវនាការជំនុំជម្រះនាត្រីមាសចុងក្រោយនៃឆ្នាំនេះ ដោយហេតុថាប្រតិទិនការងារនេះទាមទារជាដាច់ខាតថា សប្ដាហ៍នេះយ៉ាងយូរ ឯកសារត្រូវបញ្ជូនទៅសហព្រះរាជអាជ្ញាដើម្បីពិនិត្យស្របតាមវិធាន ៦៦.៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ដោយយល់ឃើញថា ប្រសិនបើត្រូវធ្វើ ដើមបណ្ដឹងរដ្ឋប្បវេណីអាចស្នើសុំនៅក្នុងសវនាការនៃដំណាក់កាលសាលក្រម អោយសួរជនជាប់ចោទរាល់សំនួរដែលខ្លួនយល់ឃើញថាចាំបាច់។ ម្យ៉ាងវិញទៀត យល់ឃើញថា មេធាវីរបស់ឌុច បានអោយដឹងថាខ្លួននឹងបញ្ជូនពាក្យសុំរបស់ដើមបណ្ដឹងរប្បវេណីទៅកូនក្ដីរបស់ខ្លួនដើម្បីអោយឌុចអាចត្រៀមឆ្លើយតាមរយៈការសរសេរទៅលើចំនុចនីមួយៗដែលបានលើកឡើង។ ជាចុងក្រោយ យល់ឃើញថា លោកស្រី **ក...** និងលោក **ខ...** បានគូសបញ្ជាក់ថាពួកគេមានបំណងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងស៊ើបសួរលេខ០០២ ដែលចំណុចនេះ អនុញ្ញាតអោយមានការស៊ើបអង្កេតបន្ថែមនានា ប្រសិនបើចាំបាច់។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

**ហេតុដូច្នេះ**

សម្រេចមិនបំពេញកិច្ចស៊ើបសួរដែលបានស្នើសុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co- Investigating Judges**

**Co-juges d'instruction**



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.